# ឯកឧត្តម ចម ប្រសិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីប្រកាស

# ចូលកាន់តំណែងក្រុមប្រឹក្សា ខេត្តកំពតអណត្តិទី២



នៅសាលាខេត្តកំពត នាព្រឹកថ្ងៃទី០៨ ខែ មិថុនា ឆ្នាំ២០១៤ ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងជាប្រធានក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋាន ដើម្បីត្រួតពិនិត្យ និង គាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាលកម្ពុជា ខេត្តកំពត បានអញ្ជើញជាអធិបតីក្នុងពិធីប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាខេត្តកំពតអណត្តិទី២ ដោយមានការចូលរួមពីឯកឧត្តម លោកជំទាវ អស់លោកលោកស្រី ជាសមាជិកក្រុមការងារថ្នាក់ជាតិ និងតំណាងអជ្ញាធរខេត្ត យ៉ាងច្រើនកុះករ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **ខូយ ឃុនហួរ** អភិបាល នៃគណៈអភិបាលខេត្តកំពត បានថ្លែងសន្ទរកថា ស្វាគមន៍ និងរាយការណ៍ជូនអង្គពិធីទាំងមូលអំពីសមិទ្ធផល ដែលរដ្ឋបាលខេត្តកំពតសម្រេចបានកន្លងទៅ ព្រមទាំងបានបញ្ជាក់បន្ថែមថា: ក្រុមប្រឹក្សាខេត្ត បានដំណើរការកិច្ចប្រជុំសាមញ្ញចំនួន ៦០លើក ប្រជុំវិសាមញ្ញ ចំនួន១២លើក ប្រជុំសម្ងាត់ចំនួន ០១លើក ព្រមទាំងបានរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខេត្តក្នុងឆ្នាំ ២០១៣ បានចំនួន០៨វេទិកា នៅតាមបណ្តាក្រុង ស្រុក ដោយទទួលបាននូវសំណួរ សំណូមពរ សរុបចំនួន៥៧ ។ ជាមួយគ្នានេះ ឯកឧត្តមអភិបាលខេត្តក៏បានលើកឡើងពីភាពប្រឈមមួយចំនួនផងដែរ ។

បន្ទាប់ពីឯកឧត្តម **ឡាយ វោហារិទ្ធ** អគ្គនាយករង នៃអគ្គនាយកដ្ឋានមូលដ្ឋានក្រសួងមហាផ្ទៃ អានព្រះរាជក្រឹត្រស្តីពីការទទួលស្គាល់សមាសភាពសមាជិកក្រុមប្រឹក្សាខេត្តចំនួនទាំង ១៧ រូប ដែលសមាសភាពមកពីគណបក្សប្រជាជនកម្ពុជាចំនួន ១៣រូប និងគណៈបក្ស សង្គ្រោះជាតិចំនួន ០៤ រូប រួចមក ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានអញ្ជើញប្រគល់ព្រះរាជក្រឹត្យដល់សមាជិកក្រុមក្រឹក្សាខេត្តជាប់ឆ្នោតនីមួយៗ ហើយតមក ឯកឧត្តម **អ៊ុង**

**ម៉េងហួរ** ជាប្រធានក្រុមប្រឹក្សាអណត្តិថ្មី បានឡើងធ្វើការប្តេជ្ញាចិត្ត ដោយបានបញ្ជាក់ពីការខិតខំប្រឹងប្រែង និងអនុវត្ត ឱ្យបានប្រសើរនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត និងសហការបំពេញការងារ សំដៅសម្រេចបាននូវផែនការអភិវឌ្ឍន៍ ខេត្តទទួលនូវលទ្ធផលជាវិជ្ជមាន ។







មានប្រសាសន៍នាឱកាសនោះ ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា បានសំដែងនូវការអបអរសាទរចំពោះសមាជិកក្រុមប្រឹក្សាខេត្តកំពត ដែលត្រូវបានតំណាងប្រជាពលរដ្ឋ គឺសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ផ្តល់សេចក្តីទុកចិត្ត បោះឆ្នោតជ្រើសរើសជាសមាជិក ក្រុមប្រឹក្សាខេត្តកំពតអណត្តិទី២ ដើម្បីបន្តដឹកនាំខេត្តកំពត ទទួលបានការអភិវឌ្ឍន៍រីកចម្រើនលើគ្រប់វិស័យបន្ថែមទៀត ។ ក្នុងនាមជាសមាជិកក្រុមប្រឹក្សាដែលជាប់ឆ្នោត ទោះជាមានសមាសភាពមកពីគណបក្សនយោបាយផ្សេងៗគ្នាក៏ពិតមែន ។ ប៉ុន្តែ តាមគោលការណ៍ច្បាប់ ក្រុមប្រឹក្សាគឺជាតំណាងឱ្យប្រជាពលរដ្ឋ ។ ហេតុនេះ ក្នុងការអនុវត្តការងារ ឯកឧត្តម លោកជំទាវ ត្រូវខិតខំបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ ដោយស្មើភាព ដោយមិនត្រូវប្រកាន់និន្នាការនយោបាយនោះឡើយ ។ ជាមួយនិងការកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ រីកចម្រើន របស់រដ្ឋបាលខេត្តកំពត ។ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានគូសបញ្ជាក់អំពីដំណើរការបោះឆ្នោត ការវិវឌ្ឍន៍នៃស្ថានភាពសេដ្ឋកិច្ចនៅកម្ពុជា និងទិសដៅជាអាទិភាពនានា សម្រាប់ជាមូលដ្ឋាន ដើម្បីយើងបន្តរួមគ្នា ថែរក្សាសន្តិភាព ស្ថិរភាព និរន្តរភាព សំដៅអភិវឌ្ឍន៍សង្គមកម្ពុជាឱ្យកាន់តែមានការរីកចម្រើន ស្របតាមបំណងប្រាថ្នារបស់ប្រជាជនគ្រប់ៗរូប ។

អំពីការងារបោះឆ្នោត ឯកឧត្តម ទេសរដ្ឋមន្ត្រី បានលើកឡើងពីភាពជោគជ័យនូវរាល់ការរៀបចំបោះឆ្នោត ទាំងសកល និងអសកលយ៉ាងទៀងទាត់ចំនួន១២លើក ដោយទទួលបានការវាយតម្លៃពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ថាដំណើរការនៃការបោះឆ្នោតនៅកម្ពុជា កាន់តែមានភាពរីកចម្រើនជាបន្តបន្ទាប់ ។ ការបោះឆ្នោតជាតិ កាលពីថ្ងៃទី២៨ ខែ កក្កដា ឆ្នាំ២០១៣ កន្លងទៅនេះ ត្រូវបានអ្នកសង្កេតការណ៍ជាតិ អន្តរជាតិប្រកបដោយវិជ្ជាជីវៈ ធ្វើការវាយតម្លៃថា ដំណើរការបោះឆ្នោតនេះ បានប្រព្រឹត្តទៅ ក្នុងបរិយាកាសប្រកបដោយសន្តិភាព សេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើ ហឹង្សា ។ ទាក់ទង និងដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលជាដំណើរការរៀបចំការដឹកនាំគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមបែបប្រជាធិបតេយ្យ ក្នុងគោលដៅលើកកំពស់អភិបាលកិច្ចល្អនៅថ្នាក់មូលដ្ឋាននោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានលើកឡើងនូវចំណុចពាក់ព័ន្ធសំខាន់ៗចំនួន ១០ចំនុច រួមមានៈអំពីក្រប ខ័ណ្ឌច្បាប់ និងកម្មវិធីកំណែ

ទម្រង់-អំពីការរៀបចំរដ្ឋបាលដែនដី-អំពីរចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ក្រោមជាតិ-អំពីថវិកា និងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ-អំពីផែនការអភិវឌ្ឍន៍រយៈពេល០៥ ឆ្នាំ និងកម្មវិធីវិនិយោគ-អំពីធន ធានមនុស្ស-អំពីការផ្ដេរមុខងារ-អំពីគណនេយ្យភាពចំពោះប្រជាពលរដ្ឋ-អំពីការផ្ដល់សេវារដ្ឋបាល និងអំពីសមាគម ក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិ ។ ទាក់ទង និងការវិវឌ្ឍន៍ស្ថានភាពសេដ្ឋកិច្ចសង្គម ឯកឧត្តម ទេសរដ្ឋមន្ត្រី បានបង្ហាញពីការសម្រេចបានរបស់កម្ពុជានូវកំណើនសេដ្ឋកិច្ចជាមធ្យមប្រមាណ៧% ក្នុងមួយឆ្នាំៗ ក្នុងរយៈពេលជាងមួយទស្សវត្សន៏ចុងក្រោយនេះ ដែលជាហេតុធ្វើឱ្យប្រាក់ចំណូលរបស់ប្រជាពលរដ្ឋម្នាក់ៗបានកើនឡើងជាលំដាប់ ។

ផ្អែកតាមរបាយការណ៍អង្កេតភាពក្រីក្រ បានរកឃើញថាៈ ក្នុងឆ្នាំ២០១២ អត្រានៃភាពក្រីក្ររបស់ប្រជាពលរដ្ឋបានថយចុះមកត្រឹមកំរិត ១៨.៦% ។ លើមូលដ្ឋាននេះអង្គការសហប្រជាជាតិ បានវាយតម្លៃថា កម្ពុជានឹង សម្រេចបាននូវគោលដៅទី១នៃការអភិវឌ្ឍន៏សហសវត្ស ដែលពាក់ព័ន្ធនិងអត្រាកាត់បន្ថយភាពក្រីក្រត្រឹមឆ្នាំ២០១៥ ។

ឆ្លៀតឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** បានណែនាំ និងបានដាក់ទិសដៅសំខាន់ៗ និងកិច្ច ការជាអាទិភាពមួយចំនួនទៀតសម្រាប់ក្រុមប្រឹក្សាអណត្តិទី២ យកទៅអនុវត្ត ដើម្បីសម្រេចបាននូវជោគជ័យ តាមផែនការអភិវឌ្ឍន៏ប្រកបដោយតម្លាភាព គណនេយ្យភាព និងមានការទទួលខុសត្រូវខ្ពស់ផងដែរ ។ ចំណុចទាំងនេះ មានការទាក់ទងជាពិសេសទៅលើការអនុវត្តឱ្យបានខ្ជាប់ខ្ជួន ទៅតាមច្បាប់ មាត្រា សេចក្តីណែនាំ និងបទបញ្ជាផ្ទៃក្នុងនានា ដែលមានការពាក់ព័ន្ធ និងដែនសមត្ថកិច្ចនៃក្រុមប្រឹក្សាខេត្ត -បង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសនានា- លើកកំពស់ការបម្រើសេវាសាធារណៈមូលដ្ឋាន និងសមត្ថភាពធនធានមនុស្សជាដើម ។

